# ច្បាប់

# ស្តីពី

# ការចាត់តាំង និង សកម្មភាព

# របស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា

ក្រុមប្រឹក្សារដ្ឋ

រដ្ឋកម្ពុជា
ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

លេខៈ ០៦ ក្រ

# ក្រឹត្យ

ក្រុមប្រឹក្សារដ្ឋ
នៃ
រដ្ឋកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨៥

## សំរេច

ប្រកាសអោយប្រើ ច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃ រដ្ឋកម្ពុជា ដែលរដ្ឋសភា នៃរដ្ឋកម្ពុជាបានអនុម័តនៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៣ នាសម័យប្រជុំលើកទី ២៤ នីតិកាលទី ១ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ១៩៩៣
ជ.ក្រុមប្រឹក្សារដ្ឋ
ប្រធាន
ហត្ថលេខា និង ត្រា : ហេង សំរិន

កន្លែងទទួល :

- ខុទ្ទកាល័យគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា
- ខុទ្ទកាល័យរដ្ឋសភា
- ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី
- គ្រប់ទីស្តីការរដ្ឋមន្ត្រីនិងស្ថាប័នថ្នាក់ប្រហាក់ប្រហែល
- គ្រប់គណៈកម្មាធិការប្រជាជនខេត្ត ក្រុង
- រដ្ឋកិច្ច
- កាលប្បវត្តិ - ឯកសារ

ដើម្បីចម្លងចែក
...ក្រុមប្រឹក្សារដ្ឋ
ចាន់ វ៉េន

រដ្ឋកម្ពុជា

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

******

# ច្បាប់

## ស្តីពី

## ការចាត់តាំង និងសកម្មភាព

## របស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា

❀❀❀❀❀

## <u>ជំពូកទី ១</u>

## បទបញ្ញត្តិទូទៅ

<u>មាត្រា១</u> . សាលាជំរះក្តីនៃរដ្ឋកម្ពុជាមាន :

- តុលាការខេត្ត ក្រុង
- តុលាការយោធា
- សាលាឧទ្ធរណ៍
- តុលាការកំពូល

<u>មាត្រា២</u> . តុលាការខេត្ត.ក្រុង និង តុលាការយោធា ជាសាលាជំរះក្តីជាន់ទាប ។

- តុលាការខេត្ត.ក្រុង ដែលត្រូវតាំងនៅខេត្ត.ក្រុង មានសមត្ថកិច្ចលាតសន្ធឹងលើដែនដីនៃខេត្ត.ក្រុងទាំងនោះ ។
- តុលាការយោធា ដែលត្រូវតាំងនៅក្រុងភ្នំពេញ មានសមត្ថកិច្ចលាតសន្ធឹងលើដែនដីនៃរដ្ឋកម្ពុជាទាំងមូល ។

<u>មាត្រា៣</u> . សាលាឧទ្ធរណ៍ និង តុលាការកំពូលដែលជាសាលាជំរះក្តីជាន់ខ្ពស់ ត្រូវតាំងនៅក្រុងភ្នំពេញ ។

សាលាឧទ្ធរណ៍ និង តុលាការកំពូល មានសមត្ថកិច្ចលាតសន្ធឹងលើដែនដីនៃរដ្ឋកម្ពុជាទាំងមូល ។

<u>មាត្រា៤</u> . សាលាជំរះក្តីគ្រប់ជាន់ថ្នាក់ ត្រូវជំនុំជំរះដោយផ្អែកលើច្បាប់ជាធរមាន និង ផ្អែកលើច្បាប់ និងបទបញ្ញត្តិទាំងឡាយដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់បានអនុម័ត ។

ក្នុងរឿងរដ្ឋប្បវេណី បើច្បាប់ ចែងមិនបានច្បាស់ ឬច្បាប់មិនបានចែង ត្រូវជំនុំជំរះដោយផ្អែកទៅតាមទំនៀមទំលាប់ ប្រពៃណី វិចារណញ្ញាណ ឬ សមធម៌ ។

<u>មាត្រា៥</u> . នៅអមសាលាជំរះក្តីជាន់ទាបនីមួយៗ ត្រូវមានអយ្យការ និងនៅអមសាលាជំរះក្តីជាន់ខ្ពស់នីមួយៗ ត្រូវមានមហាអយ្យការ ។

ក្នុងរឿងព្រហ្មទណ្ឌ ក្រុមអយ្យការជាម្ចាស់នៃបណ្តឹងអាជ្ញា និងធ្វើសេចក្តីសន្និដ្ឋានទោសដោយ

តាំងខ្លួនជាចុងចោទដើមជាដកប ។

ក្នុងរឿងរដ្ឋប្បវេណីនិងរឿងក្តីផ្សេងៗទៀត ក្រុមអយ្យការជាចុងចោទបណ្តឹងគ្រាន់តែជាអ្នកឱ្យយោបល់ បើយល់ឃើញថាជាការគួរ ។ ប៉ុន្តែក្នុងរឿងខ្លះដែលទាក់ទងរបៀបរៀបរយសាធារណៈ ក្រុមអយ្យការត្រូវតាំងខ្លួនជាចុងចោទដើម ។

## ជំពូកទី ២

### តុលាការខេត្ត.ក្រុង

<u>មាត្រា៦</u> . តុលាការខេត្ត.ក្រុងមានសមត្ថកិច្ចជំនុំជំរះបើកផ្លូវឧទ្ធរណ៍នូវរឿងព្រហ្មទណ្ឌ រឿងរដ្ឋប្បវេណី រឿងពាណិជ្ជកម្ម វិវាទរដ្ឋបាល និងវិវាទការងារ ។

តុលាការខេត្ត.ក្រុងជំនុំជំរះក្តីមានចៅក្រមម្នាក់ និងត្រូវបំពេញដោយរដ្ឋអាជ្ញា ឬ រដ្ឋអាជ្ញារងម្នាក់ និងក្រឡាបញ្ជីម្នាក់ ។

<u>មាត្រា៧</u> . សាលក្រមសំរេចសេចក្តីចំពោះមុខ បើកឱ្យប្តឹងឧទ្ធរណ៍ក្នុងរយៈពេលពីរខែ គិតពីថ្ងៃកាត់សេចក្តី ។

សាលក្រមកំបាំងមុខ បើកឱ្យប្តឹងជំទាស់ក្នុងរយៈពេល ១៥ ថ្ងៃ គិតពីថ្ងៃទទួលដំណឹង ។ បើផុតកំណត់ប្តឹងជំទាស់ អាចប្តឹងឧទ្ធរណ៍បានក្នុងរយៈពីរខែ គិតពីថ្ងៃផុតកំណត់ប្តឹងជំទាស់ ។

<u>មាត្រា៨</u> . បណ្តឹងឧទ្ធរណ៍ មានអានុភាពផ្អាកជាបណ្តោះអាសន្ននូវការអនុវត្តសាលក្រម ។

បណ្តឹងឧទ្ធរណ៍ដែលទាក់ទងដល់សេចក្តីសំរេចរបស់តុលាការ របស់ចៅក្រម ឬរបស់រដ្ឋអាជ្ញា ពុំមានអានុភាពផ្អាកសេចក្តីសំរេចទាំងនោះទេ លើកលែងតែបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយរដ្ឋអាជ្ញា ក្នុងរឿងឃុំខ្លួន ឬ ដោះលែងឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ។

បណ្តឹងឧទ្ធរណ៍ត្រូវធ្វើនៅសាលាជំរះក្តីដែលបានចេញសាលក្រមនោះ ។

អ្នកដែលមានសិទ្ធិប្តឹងឧទ្ធរណ៍ ឬប្តឹងជំទាស់ គឺរដ្ឋអាជ្ញា ឬជនទាំងឡាយដែលមានប្រយោជន៍ក្នុងរឿងក្តីមមានចុងក្តី ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវខាងបទរដ្ឋប្បវេណី ជនជាប់ចោទ មេធាវី ឬអ្នកការពារក្តី ។

ក្រៅពីរឿងព្រហ្មទណ្ឌ បើរដ្ឋអាជ្ញាតាំងខ្លួនជាចុងក្តីដើម ទើបមានសិទ្ធិប្តឹងឧទ្ធរណ៍បាន ។

## ជំពូកទី ៣

### តុលាការយោធា

<u>មាត្រា៩</u> . តុលាការយោធាមានសមត្ថកិច្ចជំនុំជំរះ បើកផ្លូវឧទ្ធរណ៍នូវបទល្មើសយោធា ។

បទល្មើសយោធា គឺជាបទល្មើសដែលប្រព្រឹត្តដោយយោធិននៅក្នុងជួរកងទ័ព ហើយដែលពាក់ព័ន្ធទៅនឹងវិន័យកងទ័ព ឬប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់កងកម្លាំងប្រដាប់អាវុធ ។

ក្នុងករណីយោធិនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌសាមញ្ញ ត្រូវតុលាការខេត្ត.ក្រុងជំនុំជំរះ ។

នីតិវិធីរបស់តុលាការយោធា ដូចគ្នានឹងនីតិវិធីរបស់តុលាការខេត្ត.ក្រុងដែរ ។

## ជំពូកទី ៤

## សាលាឧទ្ធរណ៍

មាត្រា ១០. សាលាឧទ្ធរណ៍មានសមត្ថកិច្ចជំនុំជំរះលើបណ្តឹងឧទ្ធរណ៍ អំពីសាលក្រមរបស់ តុលាការខេត្ត ក្រុង និងតុលាការយោធា ដោយបើកផ្លូវឲ្យប្តឹងសារទុក្ខ ។

មាត្រា ១១. សមាសភាពជំនុំជំរះក្តីនៃសាលាឧទ្ធរណ៍ ត្រូវមានចៅក្រម ៣ នាក់ ដែលម្នាក់ធ្វើជាប្រធាន ។ សមាសភាពនៃសាលាជំរះក្តីនេះ ត្រូវបំពេញដោយអគ្គរដ្ឋអាជ្ញា ឬអគ្គរដ្ឋអាជ្ញារង ឬរដ្ឋអាជ្ញាម្នាក់នៃមហាអយ្យការ និង ក្រឡាបញ្ជីម្នាក់ ។

ក្នុងករណីជំនុំជំរះជាថ្មីឡើងវិញ សមាសភាពជំនុំជំរះក្តីនេះ ត្រូវមានចៅក្រម ៣ នាក់ ដែលម្នាក់ធ្វើជាប្រធាន ហើយសុទ្ធតែជាចៅក្រមដែលមិនបានចូលរួមជំនុំជំរះលើកមុន ។

មាត្រា ១២. សាលដីកាសាលាឧទ្ធរណ៍សំរេចសេចក្តីចំពោះមុខ អាចប្តឹងសារទុក្ខបានក្នុងរយៈពេល ២ខែ គិតពីថ្ងៃកាត់សេចក្តី ។

សាលដីកាកំបាំងមុខ អាចប្តឹងជំទាស់បានក្នុងរយៈពេល ១៥ ថ្ងៃ គិតពីថ្ងៃទទួលដំណឹង ។ បើផុតកំណត់ប្តឹងជំទាស់ អាចប្តឹងសារទុក្ខបានក្នុងរយៈពេល ២ ខែ គិតពីថ្ងៃផុតកំណត់ប្តឹងជំទាស់ ។

មាត្រា ១៣. បណ្តឹងសារទុក្ខ មានអានុភាពផ្អាកជាបណ្តោះអាសន្ន នូវការអនុវត្តសាលដីការបស់សាលាឧទ្ធរណ៍ ។ ប៉ុន្តែបណ្តឹងសារទុក្ខដែលទាក់ទងដល់ការឃុំខ្លួនជាបណ្តោះអាសន្ន ការដាក់ឲ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ការតំកល់រឿងមិនចាត់ការ និង ការលើកលែងចោទប្រកាន់ ពុំមានអានុភាពផ្អាកការអនុវត្តសាលដីកាសាលាឧទ្ធរណ៍ឡើយ ។ បណ្តឹងសារទុក្ខត្រូវធ្វើនៅសាលាជំរះក្តីដែលបានចេញសាលដីកានោះ ។

អ្នកដែលមានសិទ្ធិប្តឹងសារទុក្ខ និងប្តឹងជំទាស់ គឺអគ្គរដ្ឋអាជ្ញាសាលាឧទ្ធរណ៍ ឬជនដែលមានប្រយោជន៍ក្នុងរឿងទាំងឡាយរួមមាន : ភាគី ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវខាងបទរដ្ឋប្ប-វេណី ជនជាប់ចោទ មេធាវី អ្នកការពារ ។

## ជំពូកទី ៥

## តុលាការកំពូល

មាត្រា ១៤. តុលាការកំពូលមានសមត្ថកិច្ចជំនុំជំរះលើបណ្តឹងសារទុក្ខ អំពីសាលដីការបស់សាលាឧទ្ធរណ៍ ដោយជំនុំជំរះតែលើអង្គច្បាប់ មិនជំនុំជំរះអំពីអង្គហេតុទេ ។

ប៉ុន្តែក្នុងរឿងក្តីដែលមានបណ្តឹងសារទុក្ខជាលើកទី ២ សាលានេះត្រូវជំនុំជំរះរួមក្រុម ដោយជំនុំជំរះទាំងអង្គហេតុ និង អង្គច្បាប់ ។

មាត្រា ១៥. បណ្តឹងសើរើធ្វើបានចំពោះសាលក្រម ឬសាលដីកាស្ថាពរ ហើយដែលមានអំណាចដាច់ខាតហើយ ។

បណ្តឹងសើរើធ្វើបានក្នុងរឿងមជ្ឈិម និងរឿងឧក្រិដ្ឋ ក្នុងករណីមួយចំនួនដែលមានចែងក្នុងច្បាប់ ។

បណ្ដឹងសើរើមិនអាចធ្វើបានចំពោះសាលក្រម ឬ សាលដីកាដែលសំរេចឱ្យរួចខ្លួននោះទេ ។

អ្នកដែលអាចប្ដឹងសើរើបានគឺ :

- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- ជនជាប់ទោស ឬ តំណាងស្របច្បាប់របស់ជនជាប់ទោស ក្នុងករណីដែលជននេះគ្មានសមត្ថភាព ។
- សហព័ទ្ធ ឪពុក ម្ដាយ កូនរបស់ជនជាប់ទោស និយាយរួមគឺជនដែលមានប្រយោជន៍ខាងផ្នែកសំភារៈ ឬខាងផ្លូវចិត្ត បើជនជាប់ទោសនោះស្លាប់ ឬបាត់ខ្លួន ។

<u>មាត្រា ១៦</u>. សមាសភាពជំនុំជំរះក្ដីរបស់តុលាការកំពូលមានចៅក្រម ៥នាក់ ដែលម្នាក់ធ្វើជាប្រធាន ។ ក្នុងករណីជំនុំជំរះរួមក្រុម សមាសភាពជំនុំជំរះក្ដីនៃតុលាការនេះ ត្រូវមានចៅក្រម ៩ នាក់ ដែលម្នាក់ធ្វើជាប្រធាន ។ សមាសភាពនៃសាលាជំរះក្ដីនេះ ត្រូវបំពេញដោយអគ្គរដ្ឋអាជ្ញា ឬអគ្គរដ្ឋអាជ្ញារង ឬ រដ្ឋអាជ្ញាម្នាក់ និងក្រឡាបញ្ជីម្នាក់ ។

## ជំពូកទី ៦
## ការតែងតាំង

<u>មាត្រា ១៧</u>. តុលាការខេត្ត.ក្រុង ត្រូវមានប្រធាន អនុប្រធាន និងចៅក្រម ដែលត្រូវបានតែងតាំងឱ្យបំពេញមុខងារ ផ្លាស់ប្ដូរ តម្លើងឋានន្តរស័ក្តិ ឬហូតងារដោយក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

អយ្យការអមតុលាការខេត្ត.ក្រុង មានរដ្ឋអាជ្ញា រដ្ឋអាជ្ញារង ដែលត្រូវបានតែងតាំងឱ្យបំពេញមុខងារ ផ្លាស់ប្ដូរ តម្លើងឋានន្តរស័ក្តិ ឬហូតងារដោយក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

<u>មាត្រា ១៨</u>. ប្រធានតុលាការនិងរដ្ឋអាជ្ញាអមតុលាការខេត្ត.ក្រុង មានឋានៈស្មើនឹងអនុប្រធានគណៈកម្មាធិការខេត្ត.ក្រុង ។

អនុប្រធានតុលាការ និង រដ្ឋអាជ្ញារងអមតុលាការខេត្តក្រុង មានឋានៈស្មើនឹងសមាជិកអចិន្ត្រៃយ៍នៃគណៈកម្មាធិការខេត្ត.ក្រុង ។

ចៅក្រមតុលាការខេត្ត.ក្រុង មានឋានៈស្មើនឹងប្រធានមន្ទីរខេត្ត.ក្រុង ។

<u>មាត្រា ១៩</u>. សាលាឧទ្ធរណ៍មានប្រធានម្នាក់ អនុប្រធាន និង ចៅក្រមដែលត្រូវបានតែងតាំង ឱ្យបំពេញមុខងារ ផ្លាស់ប្ដូរ តម្លើងឋានន្តរស័ក្តិ ឬហូតងារដោយក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

- មហាអយ្យការអមសាលាឧទ្ធរណ៍ មានអគ្គរដ្ឋអាជ្ញាម្នាក់ អគ្គរដ្ឋអាជ្ញារង និងរដ្ឋអាជ្ញាដែលត្រូវបានតែងតាំងឱ្យបំពេញមុខងារ ផ្លាស់ប្ដូរ តម្លើងឋានន្តរស័ក្តិ ឬហូតងារដោយក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

<u>មាត្រា ២០</u>. ប្រធានសាលាឧទ្ធរណ៍ និងអគ្គរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍មានឋានៈស្មើនឹងរដ្ឋមន្ត្រី ។

អនុប្រធានសាលាឧទ្ធរណ៍ និងអគ្គរដ្ឋអាជ្ញារងអមសាលាឧទ្ធរណ៍ មានឋានៈស្មើនឹងអនុរដ្ឋមន្ត្រី ។

ចៅក្រមនៃសាលាឧទ្ធរណ៍ និងរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍ មានឋានៈស្មើនឹងប្រធានតុលាការ

ខេត្ត,ក្រុង ។

មាត្រា ២១. តុលាការកំពូលមានប្រធាន អនុប្រធាន និងចៅក្រម

មហាអយ្យការអមតុលាការកំពូល មានអគ្គរដ្ឋអាជ្ញា អគ្គរដ្ឋអាជ្ញារង និងរដ្ឋអាជ្ញា ។ អនុប្រធាន ចៅក្រម នៃតុលាការកំពូល និងអគ្គរដ្ឋអាជ្ញារង រដ្ឋអាជ្ញាអមតុលាការកំពូលត្រូវបានតែងតាំង ឱ្យបំពេញមុខងារ ផ្លាស់ប្តូរ តម្លើងឋានន្តរស័ក្តិ ឬហូតងារដោយក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្រោយពីបានយោបល់ពីប្រធានតុលាការកំពូល និងអគ្គរដ្ឋអាជ្ញា ។

ប្រធានតុលាការកំពូល និងអគ្គរដ្ឋអាជ្ញាអមតុលាការកំពូល ត្រូវបានតែងតាំង ផ្លាស់ប្តូរ ហូតងារ ដោយក្រឹត្យ តាមការបោះឆ្នោតជ្រើសរើសរបស់រដ្ឋសភាក្នុងចំណោមចៅក្រម ៣នាក់ ដែលសហសេវិករបស់ខ្លួនបានបោះឆ្នោតជ្រើសរើស ។

មាត្រា ២២. ប្រធានតុលាការកំពូល និងអគ្គរដ្ឋអាជ្ញាអមតុលាការកំពូល មានឋានៈស្មើនឹងអនុប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី ។

អនុប្រធានតុលាការកំពូល និងអគ្គរដ្ឋអាជ្ញារងអមតុលាការកំពូល មានឋានៈស្មើនឹងរដ្ឋមន្ត្រី។

ចៅក្រមនៃតុលាការកំពូល និងរដ្ឋអាជ្ញាអមតុលាការកំពូល មានឋានៈស្មើនឹងចៅក្រមនៃសាលាឧទ្ធរណ៍ និងរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍ដែរ ។

មាត្រា ២៣. ក្រឡាបញ្ជីនៃសាលាជំរះក្តីនៃរដ្ឋកម្ពុជា ត្រូវតែងតាំង ផ្លាស់ប្តូរ ហូតងារ តម្លើងថ្នាក់ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងមានឋានៈស្មើនឹងប្រធានការិយាល័យ ។

## ជំពូកទី ៧

## អន្តរប្បញ្ញត្តិ

មាត្រា ២៤. ច្បាប់ព្រហ្មទណ្ឌអន្តរកាល ជាពិសេសនីតិវិធីឧទ្ធរណ៍ត្រូវអនុវត្ត ៤៥ ថ្ងៃក្រោយពីក្រុមប្រឹក្សាជាតិជាន់ខ្ពស់បានអនុម័ត ដូចនេះសំណុំរឿងទាំងអស់ ទាំងរឿងព្រហ្មទណ្ឌ រឿងរដ្ឋប្បវេណី និងរឿងយោធា ដែលតុលាការកំពូលកំពុងពិនិត្យ ទោះពិនិត្យជាលើកទី១ក្តី ឬពិនិត្យជាលើកទី២ក្តីត្រូវបញ្ជូនទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះ ។

គ្រប់សំណុំរឿងទាំងអស់ដែលបដិសេធដោយតុលាការកំពូល ហើយតុលាការកំពូលបានបញ្ជូនទៅតុលាការខេត្ត.ក្រុង ឬតុលាការយោធាជំនុំជំរះសាឡើងវិញ ប៉ុន្តែតុលាការទាំងនោះពុំទាន់បានជំនុំជំរះនៅឡើយក៏ត្រូវបញ្ជូនទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះដែរ ។

គ្រប់សេចក្តីសំរេចដែលបានធ្វើឡើងដោយតុលាការខេត្ត.ក្រុង តុលាការយោធា ឬ ដោយសភានៃតុលាការកំពូល ហើយសេចក្តីសំរេចនោះត្រូវបានតួក្តី អ្នកការពារ ឬ រដ្ឋអាជ្ញាប្តឹងតវ៉ាក្នុងរយៈពេលដោយអនុវត្តតាមមាត្រា ៤ និង ៧៥ នៃច្បាប់ ព្រហ្មទណ្ឌអន្តរកាល នោះត្រូវបញ្ជូនទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះ ។

គ្រប់សំណុំរឿងទាំងអស់ ទាំងរឿងព្រហ្មទណ្ឌ ទាំងរឿងរដ្ឋប្បវេណី ទាំងរឿងយោធាដែលតុលាការកំពូលបានទទួល និងបានចុះបញ្ជីហើយ តែក្រុមប្រឹក្សាចៅក្រមមិនទាន់បានពិនិត្យ ឬ បានពិនិត្យរួចហើយ ប៉ុន្តែសភានៃតុលាការកំពូលមិនទាន់បានជំនុំជំរះនៅឡើយ ត្រូវបញ្ជូនសំណុំរឿងទាំងនោះទៅតុលាការខេត្ត.ក្រុង ឬតុលាការយោធា ដើម្បីជំនុំជំរះ ។

## <u>ជំពូកទី៨</u>
## អវសានបញ្ញត្តិ

<u>មាត្រា២៥</u>.　បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

<u>មាត្រា២៦</u>.　ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

* * * * *

ច្បាប់នេះត្រូវបានរដ្ឋសភានៃរដ្ឋកម្ពុជាអនុម័តនៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ១៩៩៣ នាសម័យប្រជុំលើកទី ២៤ នីតិកាលទី ១ ។

ធ្វើនៅភ្នំពេញ. ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៩៣

ជ. រដ្ឋសភា

ប្រធាន

ហត្ថលេខា និងត្រា : ជា ស៊ីម

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ. ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣

អគ្គលេខាធិការក្រុមប្រឹក្សារដ្ឋ

ហត្ថលេខា និងត្រា : ចាន់ វ៉ែន

---

លេខ : ១០ ប.ល

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ.ថ្ងៃទី ១០ ខែ មិនា ឆ្នាំ ១៩៩៣

ជ. ប្រធានមន្ទីរក្រសួងយុត្តិធម៌

អនុប្រធាន

គុង ពារ